# សុន្ទរកថារបស់**ឯកឧត្តម គូម៉ាម៉ារូ យូជិ**

ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ របស់ប្រទេសជប៉ុន

២៥ មិនា ២០១៤

**សូមគោរព លោក ហួត កល្យាណ ប្រធានការិយាល័យសុខាភិបាលស្រុកប្រតិបត្តិពារាំង ខេត្តព្រៃវែង!**
**សូមគោរព លោក William Houworth នាយកមន្ទីរពេទ្យកុមារអង្គរ!**
**សូមគោរព លោក ងួន ច័ន្ទភក្ត្រា នាយករងមន្ទីរពេទ្យកុមារអង្គរ!**
**សូមគោរព លោក ហ៊ីង សាមិត្ត ប្រធានការិយាល័យសុខាភិបាលស្រុកប្រតិបត្តិព្រៃកប្បាស ខេត្តតាកែវ!**
**សូមគោរព លោកស្រី Laurene LECLERCQ ប្រធានប្រចាំតំបន់អាស៊ី អង្គការកុមារ និងអភិវឌ្ឍន៍!**
**សូមគោរព អស់លោក លោកស្រី!**

ខ្ញុំមានសេចក្តីសោមនស្សរីករាយ ដើម្បីប្រារព្ធពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយ ចំនួនបួន សម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិដែលរួមមាន "គម្រោងកែលម្អអគារវះកាត់ក្នុងមន្ទីរពេទ្យបង្អែកពារាំងខេត្តព្រៃវែង" "គម្រោងបំពាក់ម៉ាស៊ីនជំនួយការដកដង្ហើមក្នុងមន្ទីរពេទ្យកុមារអង្គរខេត្តសៀមរាប" " គម្រោងសាងសង់អគារជំងឺទូទៅ និងកុមារក្នុងមន្ទីរពេទ្យបង្អែកព្រៃកប្បាសខេត្តតាកែវ" និង "គម្រោងកែលម្អសុខភាពមាតា និងទារកតាមរយៈការពង្រឹងហេដ្ឋារចនាសម្ព័ន្ធសុខាភិបាលក្នុងខេត្តកំពង់ស្ពឺ"។

គម្រោងទាំង៤ដែលត្រូវបានចុះហត្ថលេខានៅថ្ងៃនេះ មានគោលដៅផ្តល់ជូនប្រជាជនមូលដ្ឋាននៅតាមតំបន់គោលដៅនិមួយៗនូវសេវាសុខាភិបាលដែលមានគុណភាព។ ខ្ញុំទទួលស្គាល់ថាវិស័យសុខាភិបាលគឺជាវិស័យអាទិភាពមួយសម្រាប់ការអភិវឌ្ឍប្រទេសកម្ពុជា ហើយខ្ញុំជឿជាក់ថាការកែលម្អវិស័យនេះគឺជាគន្លឹះដ៏សំខាន់ក្នុងការអភិវឌ្ឍប្រទេសកម្ពុជានាពេលអនាគត ក៏ដូចជាការលើកស្ទួយសុខុមាលភាពប្រជាជនកម្ពុជា។ ខ្ញុំសង្ឃឹមថា ជំនួយឧបត្ថម្ភរបស់ជប៉ុននឹងរួមចំណែកក្នុងការសម្រេចនូវគោលបំណងទាំងនេះ។

គម្រោងទីមួយមានថវិកាសរុប ១០៩,២១៤ ដុល្លាអាមេរិក គឺដើម្បីកែលម្អអគារវះកាត់ និងបំពាក់ឧបករណ៍វះកាត់ចំនួន៩ក្នុងមន្ទីរពេទ្យបង្អែកពារាំង ខេត្តព្រៃវែង។ យើងរំពឹងថាគម្រោងនេះនឹងបង្កើនគុណភាពនៃផ្នែកវះកាត់របស់បុគ្គលិកសុខាភិបាល ហើយនិងផ្តល់នូវសេវាវះកាត់ដ៏សម្បូរបែបសម្រាប់ប្រជាជនក្នុងតំបន់ប្រមាណ២១០,០០០នាក់។

គម្រោងទីពីរ មានថវិកាសរុប ១១៤,៣១៤ដុល្លាអាមេរិក គឺដើម្បីបំពាក់ម៉ាស៊ីនជំនួយការដកដង្ហើមចំនួន៤គ្រឿងក្នុងបន្ទប់សង្គ្រោះបន្ទាន់ និងបន្ទប់ជំងឺធ្ងន់ក្នុងមន្ទីរពេទ្យកុមារអង្គរ ខេត្តសៀមរាប។ យើងសង្ឃឹមថាគម្រោងនេះនឹងអាចជួយសង្គ្រោះជីវិតកុមារដែលមានជំងឺធ្ងន់ដែលត្រូវបានបញ្ជូនមកកាន់មន្ទីរពេទ្យនេះ។

គម្រោងទីបី មានថវិកាសរុប១១៦,១២០ដុល្លាអាមេរិក គឺដើម្បីសាងសង់អគារជំងឺទូទៅ និងកុមារដែលអាចដាក់គ្រែបានចំនួន៤៥ក្នុងមន្ទីរពេទ្យបង្អែកព្រៃកប្បាស ខេត្តតាកែវ។ យើងសង្ឃឹមថាគម្រោងនេះនឹងផ្តល់នូវសេវាថែរក្សាសុខភាពដែលមានគុណភាពសម្រាប់ប្រជាជនប្រមាណ១៦២,០០០នាក់ក្នុងខេត្តតាកែវ។

គម្រោងទី៤មានថវិកាសរុប ៩៥,៨០១ដុល្លាអាមេរិក គឺដើម្បីកែលម្អសុខភាពមាតា និងទារកតាមរយៈការសាងសង់មណ្ឌលសុខភាពមួយ និងបន្ទប់រងចាំសម្រាលចំនួន៤ក្នុងឃុំចំនួន៥ និងផ្តល់ការបណ្តុះបណ្តាលផ្នែកសម្ភពដល់ឆ្មបនៅមណ្ឌលផ្តល់សេវាសុខាភិបាលចំនួន៨ក្នុងខេត្តកំពង់ស្ពឺ។ យើងសង្ឃឹមថាគម្រោងនេះនឹងអនុញ្ញាតិឲ្យប្រជាជនមូលដ្ឋានប្រមាណ៣៨៦,០០០នាក់ទទួលបានសេវាសុខភាពបឋម ជាពិសេសសេវាថែរក្សាសុខភាពមាតា និង ទារកកាន់តែប្រសើរឡើង។

រដ្ឋាភិបាលជប៉ុនបាននិងកំពុងបន្តគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងក្នុងការអភិវឌ្ឍប្រទេសកម្ពុជាតាមរយៈការផ្តល់ជំនួយឧបត្ថម្ភសម្រាប់គម្រោងជាច្រើន។ វិស័យសុខាភិបាលគឺជាវិស័យអាទិភាពមួយក្នុងចំណោមវិស័យអាទិភាពជាច្រើនទៀតនៃជំនួយរបស់ជប៉ុនសម្រាប់កម្ពុជា ហើយដែលរដ្ឋាភិបាលជប៉ុនបាន និងកំពុងបន្តផ្តល់ជំនួយយ៉ាងសកម្មសម្រាប់វិស័យនេះតាមរយៈការសាងសង់អគារមន្ទីរពេទ្យ និងគ្លីនិកនានា និងការផ្តល់វគ្គបណ្តុះបណ្តាលជាដើម។

ខ្ញុំសង្ឃឹមថា គម្រោងទាំងនេះនឹងត្រូវបានអនុវត្តយ៉ាងរលូន និងថែទាំយ៉ាងត្រឹមត្រូវដើម្បីប្រជាជនកាន់តែច្រើនអាចទទួលបានអត្ថប្រយោជន៍ពីគម្រោងទាំងនេះ។

ជាចុងក្រោយនេះ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថាគម្រោងនេះនឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និង ប្រជាជនកម្ពុជា។ សូមអរគុណ!